ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុត**

តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ខ្ញុំបាទ និងភរិយា មានបីតិសោមនស្សរីករាយឥតឧបមា សូមសម្តែងអំណរសាទរ និងសូមគោរពកោតសរសើរ យ៉ាងជ្រាលជ្រៅបំផុត ក្នុងឱកាសដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ទទួលបាននូវពានរង្វាន់ **ប្រធានគណៈកម្មាធិការអូឡាំពិកអន្តរជាតិ** «IOC President's Trophy» ពីគណៈកម្មាធិការអូឡាំពិកអន្តរជាតិ ។

ពានរង្វាន់ដ៏ខ្ពស់បំផុតដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** ទទួលបាននាពេលនេះ មិនត្រឹមតែបានផ្តល់នូវមហាកិត្តិយសចំពោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងបានលើកកម្ពស់នូវកិត្យានុភាពជាតិ និងក៏ដូចជាមោទនភាពសម្រាប់ប្រជាពលរដ្ឋខ្មែរនៅទូទាំងប្រទេស ដែលមានថ្នាក់ដឹកនាំប្រកបដោយគតិបណ្ឌិតឆ្លាតវៃ បានដឹកនាំប្រជាជាតិកម្ពុជាឆ្ពោះទៅរកវឌ្ឍនភាព និងសម្បូរណ៍រុងរឿង ។

នាឱកាសដ៏វិសេសវិសាលនេះ យើងខ្ញុំទាំងអស់គ្នាសូមគោរពជូនពរបវរមហាប្រសើរថ្លៃថ្លាជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំង បុត្រា បុត្រី និងចៅប្រុស ចៅស្រី ជាទីស្រឡាញ់ទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវការកោតសរសើរ គោរពស្រឡាញ់ ដ៏ខ្ពង់ខ្ពស់ និងស្មោះស្ម័គ្រ អំពី ខ្ញុំបាទ និងភរិយា ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧

**ប្រាក់ សុខុន** **ខេង សំវ៉ាដា**

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh